**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខ:០១០/០៩ របក.អគគ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មេសា ឆ្នាំ ២០០៩របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មេសា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាម បេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-បានទទួលលិខិតចាត់តាំងរដ្ឋលេខាធិការមួយរូប ពីក្រសួងមហាផ្ទៃ ដើម្បីបញ្ចូលជាសមាជិកក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

-បានទទួលរបាយការណ៍បូកសរុបលទ្ធផលអនុវត្តការងារក្នុងខែមករា និងកុម្ភៈ ឆ្នាំ២០០៩ និងទិសដៅបន្ត ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។

-បានទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីដែនវិសាលភាពនៃតំបន់អាងទន្លេសាប ដែលបានប្រព្រឹត្តទៅនៅថ្ងៃពុធ ទី២២ ខែមេសា ឆ្នាំ២០០៩។

-បានទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការ ត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ ដែលបានប្រព្រឹត្តទៅនៅថ្ងៃអង្គារ ទី២១ ខែមេសា ឆ្នាំ២០០៩។

-បានទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួនចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការដែលបានប្រព្រឹត្តទៅនៅថ្ងៃច័ន្ទ ទី២០ ខែមេសា ឆ្នាំ២០០៩។

-បានទទួលលិខិតអញ្ជើញចូលរួម អង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះកុសុមៈ គ្រឹះស្ថាន ជាសាធារណៈរដ្ឋបាល ដែលបានប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែមេសា ឆ្នាំ២០០៩។

-បានទទួលលិខិតអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខា ប្រគល់-ទទួល អំណោយសប្បុរសជន ជូនមូលនិធីបាយ័ន សម្រាប់កិច្ចការសង្គមកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែមេសា ឆ្នាំ២០០៩។

-បានទទួលរបាយការណ៍ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីលទ្ធផលនៃកិច្ចប្រជុំភាពជាដៃគូសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេភាគីប្រចាំឆ្នាំ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចក្រភពអង់គ្លេស និងសំណើសម្រេចលើជម្រើសសម្រាប់កិច្ចសហប្រតិបត្តិការនាអនាគត កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩។

-បានទទួលលិខិតចាត់តាំងមន្ត្រីចូលរៀនវគ្គបណ្តុះបណ្តាលបន្តសម្រាប់ឆ្នាំ ២០០៩ នៅសាលាភូមិន្ទរដ្ឋបាល

-បានទទួលលិខិតស្នើសុំចាត់តាំងតំណាងចូលរួមប្រជុំ ដើម្បីពិភាក្សាលើការរៀបចំចងក្រងផែនការសកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១២) ពីអគ្គលេខាធិការនៃ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។

-បានទទួលលិខិតអញ្ជើញចូលរួមប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួនចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ទី២៩ ខែមេសា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០នាទី។

-បានទទួលលិខិតអញ្ជើញចូលរួមប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ២០១០-២០១២ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃព្រហស្បតិ៍ ទី៣០ ខែមេសា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០នាទី។

-បានទទួលលិខិតសុំអញ្ជើញ ឯកឧត្តមនាយកអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មកផ្តល់បទអន្តរាគមន៍ដល់សិស្សថៅក្រមជំនាន់ទី ៥ លើប្រធានបទស្តីពី “កំណែទម្រង់ច្បាប់ និង តុលាការ” នៅរសៀល ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩ នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

-បានទទួលលិខិតពីក្រសួងមហាផ្ទៃ ស្តីពីការចាត់តាំងមន្ត្រីចំនួន ៤ រូប សម្រាប់គម្រោង “ស៊ើបអង្កេត និង ពង្រឹងវិធីសាស្ត្រជាប្រពៃណី នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងកម្មវិធីសកម្មភាព” កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩។

-បានទទួលសេចក្តីចម្លងពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើរបស់អង្គការច្បាប់ សាធារណៈនៃសហគមន៍អឺរ៉ុប សុំជួយសហការពង្រឹងស្ថាប័នច្បាប់កម្ពុជា ដើម្បីផ្សព្វផ្សាយ បង្កើន និងលើកកំពស់ការយល់ដឹងលើវិស័យច្បាប់សាធារណៈ ច្បាប់សិទ្ធិមនុស្ស និងច្បាប់បរិស្ថាន តាមរយៈការបណ្តុះបណ្តាល និងការស្រាវជ្រាវនៅកម្ពុជា។

-ផ្ញើលិខិតស្នើសុំចូលជួបសម្ភាសន៍ជាមួយមន្ត្រីនៅតាមក្រសួងមួយចំនួន ដូចជា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងការធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រសួង។

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំ ក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ផ្ញើលិខិតស្នើសុំ ជូនប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ូស្មាន់ (Ombudsman) នៅកម្ពុជា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩។

-ផ្ញើលិខិតស្នើសុំជូនប្រធានគណៈកម្មការទទួលពាក្យបណ្ដឹង និងសិទ្ធិមនុស្សនៃរដ្ឋសភាជាតិ ដើម្បីជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ូស្មាន់ (Ombudsman) នៅកម្ពុជា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩។

## ខ. ការងារកំណែទម្រង់

-បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅទីស្ដីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩

-បានជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ូស្មាន់ (Ombudsman) នៅកម្ពុជា ជាមួយនឹងក្រសួងស្ថាប័នមួយចំនួន។

## គ. ផ្សេងៗ

-ចូលរួមអង្គប្រជុំអន្តរក្រសួងផ្សេងៗ។

## ២-សន្និដ្ឋាន

ក្នុងខែ មេសា ឆ្នាំ ២០០៩ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំកិច្ចប្រជុំក្រុមការងារ បច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និង តុលាការ នៅទីស្ដីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ដោយលើកយករបាយការណ៍ភាព ជឿនលឿននៃសូចនាករតាមដានរួម (JMIs)។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្ដីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ ជាពិសេសក្នុងការរៀបចំ មូលដ្ឋានទិន្នន័យស្ដីពី មុខងារស្ថាប័នរដ្ឋ

-ត្រៀមរៀបចំសន្និសីទជាតិស្ដីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨

-ត្រៀមរៀបចំប្រជុំក្រុមការងារជាន់ខ្ពស់តុលាការគំរូ

-ត្រៀមរៀបចំពិភាក្សាជាមួយក្រុមពិភាក្សាយោបល់ CCJAP

-ត្រៀមរៀបចំ National Management Board CCJAP។

រាជធានី ភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩
អ្នកធ្វើរបាយការណ៍

**ហ៊្សង សុកុល**

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**